ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ....០.១..សរ...

# សារាចរ
## ស្តីពី
## ការអនុវត្តន៍វិធានការសន្សំសំចៃថាមពលអគ្គិសនី

ចាប់ពីឆ្នាំ ២០០៤មក ប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិបានឡើងថ្លៃជាបន្តបន្ទាប់ឥតឈប់ឈរ ធ្វើឱ្យថ្លៃដើមផលិតអគ្គិសនីបានកើនឡើង សមាមាត្រទៅនឹងកំណើនថ្លៃប្រេងឥន្ធនៈដែរ។ ដើម្បីទប់ទល់មិនឱ្យមានការតម្លើងថ្លៃលក់អគ្គិសនីនៅរាជធានីភ្នំពេញ រាជរដ្ឋាភិបាលបានគ្រោងឧបត្ថម្ភធនបំពេញខាតដល់អគ្គិសនីកម្ពុជា នៅឆ្នាំ២០០៨ ប្រមាណ ២៤លានដុល្លារអាមេរិក។ ទន្ទឹមនឹងការចំណាយលើការផលិតអគ្គិសនីបានកើនឡើង ការប្រើប្រាស់អគ្គិសនីក៏បានកើនឡើងជាបន្តបន្ទាប់ដែរស្របតាមសេចក្តីត្រូវការ ធ្វើឱ្យរាជរដ្ឋាភិបាលត្រូវចំណាយថវិកាជាតិបន្ថែមទៀត ដើម្បីទប់ទល់នឹងកំណើននៃការប្រើប្រាស់ថាមពលអគ្គិសនីនេះ ។

ក្នុងស្ថានភាពដូចបានរៀបរាប់ខាងលើ រាជរដ្ឋាភិបាលមានគោលនយោបាយ ឱ្យគ្រប់ក្រសួង-ស្ថាប័នរដ្ឋទាំងអស់ទាំងនៅថ្នាក់កណ្តាល និង ខេត្ត-ក្រុង ចូលរួមក្នុងកម្មវិធីសន្សំសំចៃការប្រើប្រាស់ថាមពលអគ្គិសនី ដើម្បីកាត់បន្ថយការចំណាយថវិកាជាតិលើការប្រើប្រាស់ថាមពលអគ្គិសនី ។

អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលសំរេចដាក់ចេញនូវការណែនាំ សំរាប់សន្សំសំចៃការប្រើប្រាស់អគ្គិសនីនៅតាមបណ្តាក្រសួង-ស្ថាប័នរដ្ឋទាំងអស់ទាំងនៅថ្នាក់កណ្តាល និង ខេត្ត-ក្រុង ដែលមានខ្លឹមសារ ដូចតទៅ :

១. គ្រប់ក្រសួង-ស្ថាប័នរដ្ឋទាំងអស់នៅថ្នាក់កណ្តាល និង ខេត្ត-ក្រុង ត្រូវចូលរួមសន្សំសំចៃការប្រើប្រាស់ថាមពលអគ្គិសនី ដោយអនុវត្តការប្រើប្រាស់ឧបករណ៍បរិក្ខារអគ្គិសនីតាមវិធីសន្សំសំចៃថាមពល ដូចខាងក្រោម :

- ម៉ាស៊ីនត្រជាក់ត្រូវកំណត់សីតុណ្ហភាពត្រឹមតែកំរិត ២៥ អង្សាសេ
- បិទម៉ាស៊ីនត្រជាក់ ៣០ នាទីមុនពេលចេញពីបន្ទប់ធ្វើការងារ

- នៅគ្រប់បន្ទប់ម៉ាស៊ីនត្រជាក់ អាចបើកកង្ហារបឺតខ្យល់នៅពេលចាំបាច់ប៉ុណ្ណោះ ព្រោះប្រសិនបើបើកចោលវានឹងបឺតខ្យល់ត្រជាក់ចេញទៅក្រៅ
- មិនត្រូវដោតភ្លើងចូលកុំព្យូទ័រ ម៉ាស៊ីនបោះពុម្ព ឬម៉ាស៊ីនថតចំលងទុកចោលមិនប្រើប្រាស់ ព្រោះវាស្រូបថាមពល អស់ពី ១០-៣០ ភាគរយនៃថាមពលសរុប
- ត្រូវដកឌុយចេញនៅពេលឈប់ប្រើប្រាស់ឧបករណ៍សម្ភារៈគ្រប់ប្រភេទ
- ត្រូវប្រើពន្លឺថ្ងៃដែលចូលតាមបង្អួចអោយបានអស់លទ្ធភាព ជៀសវាងប្រើវាំងននបិទពីលើបង្អួចកញ្ចក់ហើយប្រែជាប្រើពន្លឺអគ្គិសនីសំរាប់ជំនួស ពន្លឺថ្ងៃទៅវិញ
- ប្រើប្រាស់អំពូលមានប្រសិទ្ធិភាពដែលអាចសន្សំសំចៃ និងត្រូវការថាមពលអគ្គិសនីតិច តែផ្តល់ពន្លឺដូចគ្នា
- ចំពោះការបំភ្លឺផ្លូវសាធារណៈលើកលែងតែថ្ងៃបុណ្យជាតិ ត្រូវបើកអំពូលតែមួយចំហៀងផ្លូវ ឬបើកអំពូលចំនួនតែពាក់កណ្តាល
- ការបំភ្លឺផ្លូវសាធារណៈត្រូវបើក និងបិទតាមពេលវេលាចាំបាច់ ជៀសវាងបំភ្លឺផ្លូវនៅពេលមិនទាន់ងងឹត និងនៅពេលព្រឹកឡើង មានពន្លឺថ្ងៃហើយនៅមិនទាន់បិទវិញ
- កុំបើកភ្លើងចោលដោយគ្មានការចាំបាច់ ។

២. ក្រសួងមហាផ្ទៃ អាជ្ញាធរដែនដី ត្រូវសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអគ្គិសនីកម្ពុជា ដើម្បីលុបបំបាត់ការលួចតចរន្តអគ្គិសនីពីបណ្តាញអគ្គិសនីដោយខុសច្បាប់ដែលកំពុងកើតមាននៅឡើយ ។

៣. អគ្គិសនីកម្ពុជាត្រូវមានវិធានការហ្មត់ចត់បំផុតចំពោះមន្ត្រីរបស់ខ្លួនដែលរួមគំនិតលួចតចរន្តអគ្គិសនីខុសច្បាប់ ឬឃុបឃិតក្នុងការលួចបន្ថយការប្រើប្រាស់ខុសពីបរិមាណពិត ។

៤. អគ្គិសនីកម្ពុជាត្រូវជូនដំណឹងដល់អ្នកប្រើប្រាស់អគ្គិសនីពីរម៉ោងពេលដែលមានការលំបាកក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនី និងសុំអោយជួយបញ្ឈប់ ឬផ្អាកការប្រើប្រាស់ឧបករណ៍មួយចំនួនក្នុងពេលដែលការប្រើប្រាស់មានកំរិតខ្ពស់ ។

៥. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលត្រូវចេញសេចក្តីណែនាំលំអិតដោយឡែកមួយស្តីពីការសន្សំសំចៃការប្រើប្រាស់ថាមពលអគ្គិសនី ។

៦. ក្រសួងព័ត៌មានត្រូវសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីរៀបចំផ្សព្វផ្សាយដល់អ្នកប្រើប្រាស់អគ្គិសនីនូវវិធីសន្សំសំចៃការប្រើប្រាស់ថាមពល តាមវិទ្យុ ទូរទស្សន៍ និងសារព័ត៌មាននានាឱ្យបានទូលំទូលាយ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង-ស្ថាប័នរដ្ឋទាំងអស់ទាំងនៅថ្នាក់កណ្ដាល និង ខេត្ត-ក្រុង ត្រូវបង្កើនកិច្ចសហការចាត់ចែងអនុវត្តតាមស្មារតី និងខ្លឹមសារដូចបានចែងខាងលើឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួងស្ថាប័ន និង សាលា ខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ